**សុន្ទរកថាគន្លឹះ**
**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និង ជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**
**ថ្លែងក្នុង**
**«ពិធីដាក់ឱ្យដំណើរការជាផ្លូវការ នូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម»**
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០២៣
នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

- ឯកឧត្តម UENO Atsushi (**អ៊ូអិណុ អាត់ស៊ូស៊ី**) ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពនៃប្រទេសជប៉ុន ប្រចាំកម្ពុជា;
- លោកស្រី Kerry Pelzman (**ឃើរី ផែលស៍មេន**) ភារធារីស្តីទីនៃស្ថានទូតសហរដ្ឋអាម៉េរិក និង ជានាយិកាទីភ្នាក់ងារសហរដ្ឋអាម៉េរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ប្រចាំកម្ពុជា;
- លោកស្រី Jyotsana Varma (**ជុតសាណា វ៉ាម៉ា**) នាយកធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានសេចក្តីសោមនស្សជាអនេក ដោយបានចូលរួមជាអធិបតី ក្នុង **ពិធីដាក់ឱ្យដំណើរការជាផ្លូវការ នូវគម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** ។ ឆ្លៀតក្នុងឱកាសដ៏ប្រពៃនេះ, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី,** ថ្នាក់-

ដឹកនាំ, តំណាងដៃគូអភិវឌ្ឍន៍, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ដែលបានឆ្លៀតពេលដ៏មានតម្លៃ ចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នេះ ។

ដូច **ឯកឧត្តម ចន ណារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម និង ជាប្រធានក្រុមការងារបច្ចេកទេសសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម, បានគូសបញ្ជាក់នៅក្នុងរបាយការណ៍មុននេះបន្តិច, ការដាក់ឱ្យដំណើរការជាផ្លូវការ នូវ **គម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** គឺជាផ្នែកមួយនៃរបៀបវារៈគាំពារសង្គមឌីជីថល និង ជាជំហានដ៏សំខាន់ ស្របតាមបរិបទសកល ក៏ដូចជាក្នុងក្របខណ្ឌនៃការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ។

ក្នុងឱកាសដ៏វិសេសនេះ, ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម, ក្រុមការងារបច្ចេកទេសអន្តរក្រសួង និង ក្រុមការងារនៃបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ និង បណ្តាដៃគូអភិវឌ្ឍន៍នានា រួមមាន៖ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍអន្តរជាតិ (GIZ) និង ទីភ្នាក់ងារសហរដ្ឋអាម៉េរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID), ដែលបានចូលរួមគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថល និង ឌីជីថលូបនីយកម្ម ក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា ជាមួយនឹងការកសាងប្រព័ន្ធអន្តរប្រតិបត្តិការ និង ការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម ដែលត្រូវបានដាក់ឱ្យអនុវត្តសាកល្បង ប្រកបដោយជោគជ័យតាមការរំពឹងទុក កាលពីខែ មេសា ឆ្នាំ ២០២៣ កន្លងទៅថ្មីៗ ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!**

ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមនៅកម្ពុជា បានបោះជំហានទៅមុខយ៉ាងល្អ និង មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និង ឈ្លាសវៃ ប្រកបដោយភាពប្រាកដនិយម និង ចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការចូលរួមសហការអនុវត្ត ប្រកបដោយស្មារតីបុរេសកម្ម ពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍ និង គ្រប់តួអង្គពាក់ព័ន្ធដទៃទៀត ។ ជាមួយនឹងវឌ្ឍនភាពគួរជាទីមោទនៈ,

កម្ពុជាមានសមត្ថភាពគ្រប់គ្រងសភាពការណ៍ ប្រឈមនឹងវិបត្តិនានា បានយ៉ាងប្រសើរ ប្រកបដោយភាពម្ចាស់ការ និង បានកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ពីវិបត្តិនៃជំងឺកូវីដ-១៩ មកលើសង្គម-សេដ្ឋកិច្ច ឱ្យនៅកម្រិតអប្បបរមា ដែលអាចគ្រប់គ្រងបាន តាមរយៈការដាក់ចេញនូវវិធានការអន្តរាគមន៍ចាំបាច់នានា, បានទាន់ពេល និង ចំទិសដៅ, ជាបន្តបន្ទាប់ ប្រកបដោយជោគជ័យ, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពខ្ពស់ ។ ទន្ទឹមនេះ, របៀបវារៈគាំពារសង្គមឌីជីថល ក៏បាន និង កំពុងរួមចំណែកជាកាតាលីករគាំទ្រដ៏សំខាន់ ដល់ការអនុវត្តកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គម តាមរយៈការគ្រប់គ្រងបាននូវទិន្នន័យចុះបញ្ជី និង ប្រតិបត្តិការ ដែលបានផ្តល់អត្ថ-ប្រយោជន៍ផ្នែកគាំពារសង្គមនានា ប្រកបដោយបរិយាប័ន្ន, តម្លាភាព និង ប្រសិទ្ធភាព ។

ទោះជាយ៉ាងនេះក្តី, ការគ្រប់គ្រងកិច្ចអន្តរាគមន៍គាំពារសង្គមរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ កំពុងតែដំណើរការតាមរយៈប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានផ្សេងៗគ្នា ដោយពុំទាន់មានអន្តរប្រតិបត្តិការរវាងគ្នា ឱ្យបានពេញលេញនៅឡើយ និង អាចមានភាពបែកខ្ញែកថែមទៀត នៅពេលដែលវិសាលភាពនៃប្រព័ន្ធគាំពារសង្គមត្រូវបានពង្រីក នាអនាគត ។ ក្នុងបរិការណ៍នេះ, ដើម្បីសម្រេចបាននូវគោលដៅនៃការកសាងប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម ដែលមានភាពសុខដុមឈរលើអភិក្រមសមាហរណកម្ម, បរិយាប័ន្ន និង ឧត្តមានុវត្តន៍, រាជរដ្ឋាភិបាលបានគិតគូរ និង រៀបចំកសាងប្រព័ន្ធអន្តរប្រតិបត្តិការអេកូឡូស៊ីរួម នៃការចុះបញ្ជី និង គ្រប់គ្រងទិន្នន័យ ក្នុងប្រព័ន្ធគាំពារសង្គម ដោយចាប់ផ្តើមក្នុងឆ្នាំ ២០២០ តាមរយៈការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដែលមានឈ្មោះថា **ក្រុមការងារបច្ចេក-ទេស សម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** ដោយមានសមាសភាពចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ចំនួន ១១ ។

កន្លងមក, ខ្ញុំតែងទទួលបាននូវរបាយការណ៍ការងារជាបន្តបន្ទាប់ ពីអគ្គ-លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម អំពីវឌ្ឍនភាពការងារ និង កិច្ចសហការជិតស្និទ្ធ ពីសំណាក់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាសមាជិកនៃក្រុមការងារបច្ចេកទេសខាងលើ ។ ជាក់ស្តែង, រហូតមកដល់ពេលនេះ, សមិទ្ធផលសំខាន់ៗ ចំនួន ៣ បានកើតចេញជារូបរាង ក្នុងនោះ រួមមាន៖

១- **ឯកសារទស្សនាទានសម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** ដែលត្រូវបានសិក្សា, វិភាគ និង វាយតម្លៃ យ៉ាងលម្អិត, ម៉ត់ចត់ និង គ្រប់ជ្រុងជ្រោយ តាមរយៈការប្រមូលធាតុចូល និង ការពិគ្រោះយោបល់ជាមួយគ្រប់ភាគីពាក់ព័ន្ធ រួមទាំងការសំយោគនូវឧត្តមានុវត្តន៍អន្តរជាតិពីបណ្តាប្រទេសជឿនលឿន ដែលមានប្រព័ន្ធគាំពារសង្គមរឹងមាំ និង ដោយមានការចូលរួមផ្តល់យោបល់ ពីសំណាក់ក្រុមហ៊ុនប្រឹក្សាអន្តរជាតិ Ernst & Young ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB);

២- **ការអភិវឌ្ឍថ្នាលគាំពារសង្គមឌីជីថល ជាថ្នាលស្នូល** ដែលអនុញ្ញាតឱ្យប្រតិបត្តិករសន្តិសុខសង្គម និង ជំនួយសង្គម ក៏ដូចជាស្ថាប័នពាក់ព័ន្ធ ប្រើប្រាស់ដើម្បីចុះបញ្ជីប្រជាជនគោលដៅ និង អត្ថគាហក ក្នុងវិសាលភាពនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គម និង របបសន្តិសុខសង្គម; និង

៣- **ការអភិវឌ្ឍមូលដ្ឋានផ្លាស់ប្តូរទិន្នន័យចុះបញ្ជីគាំពារសង្គម ជាមូលដ្ឋានទិន្នន័យគោល** ដែលអនុញ្ញាតឱ្យមូលដ្ឋានទិន្នន័យរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងប្រព័ន្ធគាំពារសង្គម អាចធ្វើអន្តរប្រតិបត្តិការ និង ផ្លាស់ប្តូរទិន្នន័យ រវាងគ្នានឹងគ្នាបាន ។

ជាគោលការណ៍, មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គមដែលត្រូវបានរៀបចំឡើងមកនេះ នឹងបម្រើដល់ការធ្វើស្តង់ដានីយកម្មទិន្នន័យ (Data Standardization), ការផ្ទៀងផ្ទាត់ទិន្នន័យចុះបញ្ជី, ពិសេស ទិន្នន័យអត្តសញ្ញាណ, ការច្រោះទិន្នន័យចុះបញ្ជី និង ការបញ្ចៀសទិន្នន័យស្ទួន (Data De-duplication), និង ការបង្កើតលេខសម្គាល់គាំពារសង្គមតែមួយគត់ ដែលមាន ១០ ខ្ទង់ (10-digit Unique SPID) សម្រាប់ប្រជាជនគោលដៅ និង អត្ថគាហកម្នាក់ៗ ។ ការបង្កើតឱ្យមានមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គមនេះ គឺជាគន្លងអន្តរប្រតិបត្តិការថ្មី ក្នុងប្រព័ន្ធគាំពារសង្គមទាំងមូល ។ ដូច្នេះ, ក្រសួង-ស្ថាប័ន ដែលជាប្រតិបត្តិករ ត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ ក្នុងការតភ្ជាប់ និង ទាញយកនូវអត្ថប្រយោជន៍ ពីមុខងារសំខាន់ៗទាំងអស់នេះ ដើម្បីឈានទៅសម្រេចបាន នូវវឌ្ឍនភាពមួយជំហានទៀត ក្នុងការអនុវត្តគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាល ប្រកបដោយតម្លាភាព, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!**

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលជាសារវន្តទាំងនេះ, ក្រុមប្រឹក្សាជាតិគាំពារសង្គម ក៏បានចាប់ផ្តើមអនុវត្តសាកល្បង នូវ **គម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយមានការវិភាគ និង ការសិក្សាយ៉ាងល្អិតល្អន់ ជាមួយនឹងការចូលរួមអនុវត្តយ៉ាងសកម្ម ពីសំណាក់អង្គភាព និង ស្ថាប័ន ចំនួន ៥ រួមមាន៖ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ, អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ, បេឡាជាតិសន្តិសុខសង្គម, មូលនិធិជាតិជំនួយសង្គម, និង ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ព្រមជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងឃុំ-សង្កាត់ពាក់ព័ន្ធ ដែលកិច្ចការនេះកំពុងហុចលទ្ធផលយ៉ាងល្អ ដូច **ឯកឧត្តម ចន ណារិទ្ធ** បានគូសរំលេចនៅក្នុងរបាយការណ៍ ពីខាងដើម ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំសូមគូសបញ្ជាក់ថា ការធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម នឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់ ក្នុងការអនុវត្តគោលនយោបាយជាតិគាំពារសង្គម ប្រកបដោយគណនេយ្យភាព, តម្លាភាព, អភិបាលកិច្ចល្អ, បរិយាប័ន្ន និង ភាពប្រទាក់ក្រឡាគ្នា ។ ជាមួយនឹងទស្សនវិស័យនៃការធ្វើអន្តរប្រតិបត្តិការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ, ខ្ញុំក៏សូមបញ្ជាក់ផងដែរថា កិច្ចសហការ និង អន្តរប្រតិបត្តិការរវាងមនុស្ស (Human Interoperability) គឺជាកត្តាដ៏សំខាន់ មិនអាចខ្វះបាន ពីព្រោះ ការធ្វើអន្តរប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ប្រព័ន្ធផ្សេងៗទៀត នឹងពុំអាចធ្វើទៅបានឡើយ បើមនុស្ស និង ស្ថាប័នពុំទាន់មានកិច្ចសហការស៊ីចង្វាក់គ្នាជាធ្លុងមួយ និង ពុំទាន់មានការចូលរួមអនុវត្ត ឱ្យបានពេញលេញ និង ស្រុះគ្នា ប្រកបដោយស្មារតីបុរេសកម្ម ។

អាស្រ័យហេតុនេះ, ខ្ញុំសូមលើកទឹកចិត្ត និង ស្នើក្រសួង-ស្ថាប័ន ព្រមទាំងក្រុមការងារពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តគោលនយោបាយជាតិគាំពារសង្គម ដែលនឹងប្រើប្រាស់ថ្នាលគាំពារសង្គមឌីជីថល និង មូលដ្ឋានទិន្នន័យគាំពារសង្គម យកចិត្តទុកដាក់លើការងារចម្បងមួយចំនួន ដូចខាងក្រោម៖

១- បន្តនូវកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ដើម្បីធានាបាននូវភាពជោគជ័យ ក្នុងដំណើរការកសាងប្រព័ន្ធគាំពារសង្គមកម្ពុជា តាមរយៈឌីជីថលូបនីយកម្ម

ពេញលេញ សំដៅបង្កើនប្រសិទ្ធភាព និង ពង្រីកវិសាលភាពបន្ថែមទៀតជាជំហានៗ;

២- បន្តពិនិត្យ និង សិក្សាអំពីផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថល ក្នុងប្រព័ន្ធគាំពារសង្គម ដែលកំពុងត្រូវបានរៀបចំ ក៏ដូចជាបទប្បញ្ញត្តិពាក់ព័ន្ធ និង លើកជាអនុសាសន៍ សម្រាប់ការអភិវឌ្ឍ, ការអនុវត្ត និង ការដោះស្រាយបញ្ហាឆ្លងវិស័យ (Cross-cutting Issues) ឱ្យមានប្រសិទ្ធភាព ដើម្បីបង្កើនសង្គតិភាព និង ស័ក្តិសិទ្ធិភាព, ទាំងក្នុងទិដ្ឋភាពនៃការអនុវត្តគោលនយោបាយជាតិគាំពារសង្គម និង ទិដ្ឋភាពគាំពារសង្គមឌីជីថល;

៣- ប្រើប្រាស់ថ្នាលគាំពារសង្គមឌីជីថល ដើម្បីបម្រើដល់ការចុះបញ្ជី និង ដើម្បីកាត់បន្ថយបន្ទុក និង សម្ពាធរបស់មន្ត្រីមូលដ្ឋាន ដែលជាអ្នកអនុវត្ត និង ត្រៀមតភ្ជាប់ និង ធ្វើអន្តរប្រតិបត្តិការ ជាមួយមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម ដោយធ្វើសមកាលកម្ម និង បច្ចុប្បន្នកម្មទិន្នន័យ (Data Synchronization and Update) ក្នុងពេលជាក់ស្តែង (Real-time);

៤- ក្រុមការងារបច្ចេកទេសអន្តរក្រសួង សម្រាប់ធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម ត្រូវត្រៀមសហការជិតស្និទ្ធ និង ផ្តល់ការគាំទ្របន្ថែម ប្រកបដោយស្មារតីបុរេសកម្ម ដើម្បីឈានទៅពង្រីកវិសាលភាពនៃគម្រោងដ៏មានសារៈសំខាន់នេះ ជាដំណាក់កាលបន្តបន្ទាប់ នៅទូទាំងប្រទេស; និង

៥- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និង ជាលេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសអន្តរក្រសួង ត្រូវត្រៀមលក្ខណៈឱ្យបានរួចរាល់ ដើម្បីផ្តល់ការគាំទ្រឱ្យបានទាន់ពេល និង បន្តសម្របសម្រួលការងារនេះ សំដៅលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការធ្វើឌីជីថលូបនីយកម្ម ក្នុងប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យបានកាន់តែប្រសើរឡើងជាលំដាប់ ស្របតាមក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមថ្លែងអំណរគុណ **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី**ទាំងអស់ ដែលបានចូលរួមក្នុង **ពិធីដាក់ឱ្យដំណើរការជាផ្លូវការ នូវ**

**គម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** នាឱកាសនេះ និង សូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍, ជាពិសេស មូលនិធិរដ្ឋាភិបាលជប៉ុនសម្រាប់ភាពរុងរឿង និង ភាពធន់នៅអាស៊ី និង ប៉ាស៊ីហ្វិក តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍអន្តរជាតិ (GIZ) និង ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដែលតែងតែសហការ និង គាំទ្រការងារដ៏មានសារៈសំខាន់នេះ ។ ជាមួយគ្នានេះដែរ, ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការគិតគូរ, រៀបចំ និង អនុវត្តគម្រោងនេះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងធ្វើសុខដុមនីយកម្មនេះ នឹងដំណើរការដោយរលូន ប្រកបដោយផ្លែផ្កា តាមការរំពឹងទុក ។

ជាទីបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យជូន **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី** ប្រកបដោយសុខភាពល្អបរិបូណ៌, សុភមង្គលក្នុងក្រុមគ្រួសារ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញលេញទូទាំងផ្ទៃប្រទេស ដែលនាំមកជូនប្រជាជន និង ប្រទេសជាតិយើង ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវ **គម្រោងធ្វើសុខដុមនីយកម្មប្រព័ន្ធចុះបញ្ជី និង គ្រប់គ្រងទិន្នន័យគាំពារសង្គម** ដោយភ្ជាប់ជាមួយនូវការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **ថ្នាលគាំពារសង្គមឌីជីថល** និង **មូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**